ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥៧០ ....សហវ-ប្រក

# ប្រកាស
## ស្តីពី
## ការកំណត់វិធាននិងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញ សម្រាប់អ្នកជាប់ពន្ធតូច

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលដៅ

ប្រកាសនេះមានគោលដៅកំណត់នូវវិធាននិងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញ ស្របតាមបទប្បញ្ញត្តិនៃមាត្រា៦ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។

### ប្រការ ២.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវវិធាននិងនីតិវិធីកត់ត្រាបញ្ជីគណនេយ្យសាមញ្ញ ដែលបង្កើតឡើងដើម្បីជួយសម្រួលដល់អ្នកជាប់ពន្ធក្នុងកិច្ចប្រតិបត្តិការអាជីវកម្មតូចៗឬអាជីវកម្មដែលមានលក្ខណៈគ្រួសារ។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតូចដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៤.- វិធាននិងគោលការណ៍នៃបញ្ជីគណនេយ្យសាមញ្ញ

អនុលោមតាមមាត្រា៦ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ វិធាននិងគោលការណ៍នៃបញ្ជីគណនេយ្យសាមញ្ញត្រូវបានកំណត់ដូចខាងក្រោមនេះ÷

១- បញ្ជីគណនេយ្យសាមញ្ញជាប្រភេទបញ្ជីគណនេយ្យឯកភាគដែលមានខ្ទង់នានាសម្រាប់កត់ត្រាប្រចាំថ្ងៃនូវប្រតិបត្តិការអាជីវកម្ម អមដោយវិក្កយបត្រឬសក្ខីបត្របញ្ជាក់ច្បាស់លាស់អំពីចំណូលនិងចំណាយនានា។ បញ្ជីគណនេយ្យសាមញ្ញ រួមមាន ៣ បញ្ជីគឺ÷

- ក- បញ្ជីទិញប្រចាំថ្ងៃ (Purchases Day Book) ÷ គឺជាកំណត់ត្រាដែលអ្នកជាប់ពន្ធត្រូវធ្វើការកត់ត្រាជាប្រចាំថ្ងៃនូវរាល់ចំណាយដែលកើតមានឡើងក្នុងគោលដៅប្រកបអាជីវកម្មរបស់ខ្លួនដូចជាចំណាយលើ ទ្រព្យអចលកម្ម ការទិញទំនិញសម្រាប់លក់ឬសម្រាប់ផ្គត់ផ្គង់សេវា វត្ថុធាតុដើម បុគ្គលិក-កម្មករ ទឹក-ភ្លើង ការជួលចលនឬអចលនទ្រព្យ និងចំណាយផ្សេងៗ។
- ខ- បញ្ជីលក់ប្រចាំថ្ងៃ (Sales Day Book) ÷ គឺជាកំណត់ត្រាដែលអ្នកជាប់ពន្ធត្រូវធ្វើការកត់ត្រា

ជាប្រចាំថ្ងៃ នូវរាល់ប្រតិបត្តិការនៃការផ្គត់ផ្គង់ទំនិញឬសេវាតាមវិក្កយបត្រនីមួយៗក្នុងករណីផ្គត់ផ្គង់ទំនិញឬសេវាដែលមានតម្លៃខ្ពស់ ឬកត់ត្រាសរុបក្នុងមួយថ្ងៃម្តងក្នុងករណីផ្គត់ផ្គង់ទំនិញឬសេវាមានតម្លៃទាបឬលក់រាយច្រើនមុខលើវិក្កយបត្រតែមួយ។

គ- បញ្ជីស្តុកទំនិញ (Inventory Book) ÷ គឺជាកំណត់ត្រាដែលអ្នកជាប់ពន្ធត្រូវធ្វើការកត់ត្រានូវព័ត៌មានមួយចំនួនទាក់ទិនទៅនឹងស្តុកទំនិញដើមគ្រា ទំនិញដែលបានទិញក្នុងគ្រា និងស្តុកទំនិញចុងគ្រា។

២- ក្នុងការគណនាប្រាក់ចំណេញឬមូលដ្ឋានដើម្បីគិតពន្ធអាករនានា អ្នកជាប់ពន្ធត្រូវអនុវត្តតាមវិធាន និងនីតិវិធីដែលមានចែងក្នុងប្រការទាំងឡាយខាងក្រោម និងតាមគំរូនិងសេចក្តីណែនាំអំពីការកាន់កត់ត្រាបញ្ជីគណនេយ្យសាមញ្ញដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ផ្នែកទី២
## ពន្ធលើប្រាក់ចំណេញ

### ប្រការ ៥.- គោលការណ៍អំពីពន្ធកាត់ទុក

វៀរលែងតែពន្ធកាត់ទុកលើថ្លៃឈ្នួលចលននិងអចលនទ្រព្យដូចមានចែងក្នុងមាត្រា ២៥ថ្មី និងមាត្រា ២៦ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវបានអនុគ្រោះពីកាតព្វកិច្ចជាភ្នាក់ងារកាត់ទុក។

### ប្រការ ៦.- គោលការណ៍សម្រាប់ទ្រព្យអចលកម្ម

ទ្រព្យអចលកម្មគឺទ្រព្យរូបីឬអរូបីដែលប្រើប្រាស់សម្រាប់ប្រកបអាជីវកម្ម ដែលមានអាយុកាលប្រើប្រាស់លើសពីមួយឆ្នាំឡើងទៅ។ ទ្រព្យអចលកម្មត្រូវបានអនុញ្ញាតឱ្យធ្វើរំលស់នៅពេលទ្រព្យទាំងនោះត្រូវបានដាក់ប្រើប្រាស់។

គោលការណ៍សម្រាប់រំលស់ទ្រព្យអចលកម្ម ត្រូវបានកំណត់ដូចខាងក្រោម÷

១- ទ្រព្យអចលកម្មដែលអាចរំលស់បានគឺជាទ្រព្យអចលកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម វៀរលែងតែដីធ្លី អគារ តូបលក់ទំនិញ និងរថយន្តទេសចរណ៍។

២- ចំពោះទ្រព្យអចលកម្មដែលមានស្រាប់មុនការចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបានអនុញ្ញាតឱ្យយកមកធ្វើរំលស់ដោយវាយតម្លៃស្មើនឹង ៥០ ភាគរយ នៃថ្លៃដើមពេលទិញចូល ឬយកតាមតម្លៃទីផ្សារ។ ចំពោះអ្នកជាប់ពន្ធដែលបានចុះបញ្ជីជារបបស្វ័យប្រកាសមុនពេលប្រកាសនេះចូលជាធរមាន ត្រូវយកតម្លៃពិតនៃទ្រព្យអចលកម្មដែលនៅសល់មកធ្វើជាមូលដ្ឋានរំលស់។

៣- ត្រូវបានអនុញ្ញាតឱ្យកត់ត្រាជាទ្រព្យអចលកម្ម ចំពោះតែទ្រព្យណាដែលបានទិញមកដើម្បីបម្រើអោយ

សកម្មភាពអាជីវកម្មសុទ្ធសាធ និងមានតម្លៃសរុបពេលទិញចូលចាប់ពី ១ ០០០ ០០០ (មួយលាន) រៀល ឡើងទៅក្នុងមួយឯកតាដោយរួមបញ្ចូលទាំងពន្ធអាករនានា។ បើទ្រព្យមានតម្លៃក្រោមនេះ ត្រូវកត់ត្រាចូលជាចំណាយផ្សេងៗ។

៤- ត្រូវបានអនុញ្ញាតឱ្យកត់ត្រាជាទ្រព្យអចលកម្មចំពោះតែម្ចាស់ទ្រព្យប៉ុណ្ណោះ វៀរលែងតែក្នុងករណីភតិសន្យាហិរញ្ញវត្ថុដែលអ្នកទទួលជួលទ្រព្យអចលកម្មជាអ្នកទទួលហានិភ័យក្នុងការបាត់បង់ឬខូចខាត។

**ប្រការ ៧.- រំលស់**

អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យធ្វើរំលស់ទ្រព្យអចលកម្ម ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យបង្កើតគណនីរំលស់ទ្រព្យអចលកម្ម (Pooled Asset Account) ដែលគណនីនេះបង្ហាញនូវតម្លៃពិតនៃទ្រព្យអចលកម្មទាំងអស់ ដែលរួមមានតម្លៃទ្រព្យដែលយោងសល់ពីឆ្នាំមុន បូក តម្លៃទិញទ្រព្យអចលកម្មក្នុងឆ្នាំចរន្ត ដក តម្លៃទ្រព្យដែលលក់ឬឈប់ប្រើប្រាស់។

២- រំលស់ត្រូវបានអនុញ្ញាតឱ្យគិតមួយឆ្នាំពេញ ក្នុងឆ្នាំដែលទ្រព្យអចលកម្មបានដាក់ប្រើប្រាស់ក្នុងអាជីវកម្ម។

៣- រំលស់ត្រូវអនុវត្តតាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ៣០ ភាគរយ។

៤- ប្រសិនបើតម្លៃពិតនៃទ្រព្យអចលកម្មសរុបដែលនៅសល់ក្នុងគណនីរំលស់ ស្មើឬតិចជាង ១ ០០០ ០០០ (មួយលាន) រៀល តម្លៃនៅសល់នេះអាចត្រូវបានអនុញ្ញាតឱ្យកត់ត្រាជាចំណាយរំលស់ផ្តាច់ក្នុងការិយបរិច្ឆេទតែម្តង។

**ប្រការ ៨.- ចំណាយចរន្ត**

ចំណាយចរន្ត គឺជាចំណាយនានាដែលអ្នកជាប់ពន្ធបានធ្វើឡើងក្នុងឆ្នាំជាប់ពន្ធតែក្នុងគោលដៅបម្រើអាជីវកម្មប៉ុណ្ណោះ។ ចំណាយទាំងនេះ រួមមាន÷

- ថ្លៃដើមទំនិញឬសេវាដែលបានផ្គត់ផ្គង់
- ចំណាយលើបុគ្គលិក
- ចំណាយលើទឹក-ភ្លើង
- ចំណាយលើការជួល
- ចំណាយលើសេវា និង
- ចំណាយផ្សេងៗ ដូចជា ចំណាយការប្រាក់ សោហ៊ុយ ប្រាក់ប៉ះប៉ូវឬសំណងនានា។ល។

## ប្រការ ៩.- ស្តុកទំនិញ

ក្នុងការប្រកបអាជីវកម្ម អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យកាន់បញ្ជីស្តុកទំនិញតាមគោលការណ៍ដូចខាងក្រោម÷

១- សម្រាប់សហគ្រាសដែលធ្វើការផ្គត់ផ្គង់ទំនិញត្រូវកាន់បញ្ជីស្តុកទំនិញ។ សហគ្រាសដែលធ្វើការផ្គត់ផ្គង់សេវាសុទ្ធសាធមិនចាំបាច់កាន់បញ្ជីស្តុកទំនិញទេ។

២- ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់ទំនិញផងនិងសេវាផង ត្រូវកំណត់ទៅតាមផលធៀបនៃចំនួនប៉ាន់ស្មាននៃផលរបរដែលបានមកពីការលក់ទំនិញ ទៅនឹងចំនួនប៉ាន់ស្មាននៃផលរបរសរុប (ទំនិញនិងសេវា) តាមមូលដ្ឋានខែឬឆ្នាំ។ ប្រសិនបើចំនួនប៉ាន់ស្មាននៃផលរបរដែលបានមកពីការលក់ទំនិញ ស្មើឬតិចជាង ១០ ភាគរយ នៃចំនួនប៉ាន់ស្មាននៃផលរបរសរុប សហគ្រាសអាចមិនកាន់បញ្ជីស្តុកទំនិញបាន។

## ប្រការ ១០.- ការគណនាថ្លៃដើមទំនិញដែលបានលក់ឬប្រើប្រាស់សម្រាប់ផ្គត់ផ្គង់សេវា

ដើម្បីគណនាថ្លៃដើមទំនិញដែលបានលក់ឬប្រើប្រាស់សម្រាប់ផ្គត់ផ្គង់សេវា ត្រូវយកតម្លៃស្តុកទំនិញដើមគ្រា បូក តម្លៃទំនិញដែលបានទិញក្នុងគ្រា ដក តម្លៃស្តុកទំនិញចុងគ្រា។

ការកំណត់តម្លៃស្តុកទំនិញត្រូវអនុវត្តដូចខាងក្រោម÷

ក- ស្តុកទំនិញដើមគ្រា÷ រាប់ទំនិញទាំងអស់ដែលមានក្នុងស្តុកនាដើមគ្រាទៅតាមមុខទំនិញនីមួយៗ ហើយគណនារកតម្លៃសរុបដោយប្រើតម្លៃដែលបានទិញនៅលើវិក្កយបត្រទិញចុងក្រោយបង្អស់

ខ- ទំនិញទិញក្នុងគ្រា÷ ស្រង់យកទំនិញដែលបានទិញក្នុងគ្រាពីបញ្ជីទិញប្រចាំថ្ងៃក្នុងឆ្នាំមកបូកសរុបបញ្ចូលគ្នាទៅតាមតម្លៃជាក់ស្តែងលើវិក្កយបត្រទិញទំនិញ

គ- ស្តុកទំនិញចុងគ្រា÷ រាប់ទំនិញទាំងអស់ដែលនៅសល់ក្នុងស្តុកនាចុងគ្រាទៅតាមមុខទំនិញនីមួយៗ ហើយគណនារកតម្លៃសរុបដោយប្រើតម្លៃដែលបានទិញនៅលើវិក្កយបត្រទិញចុងក្រោយបង្អស់នៅក្នុងបញ្ជីទិញប្រចាំថ្ងៃ។

## ប្រការ ១១.- ការគណនាប្រាក់ចំណេញជាប់ពន្ធ

ក្នុងការគណនាប្រាក់ចំណេញជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធណាមួយ អ្នកជាប់ពន្ធត្រូវយកប្រាក់ចំណូលសរុបប្រចាំឆ្នាំនោះ ដក ថ្លៃដើមទំនិញឬសេវាបានលក់ ដក ចំណាយចរន្ត ដក រំលស់ទ្រព្យអចលកម្ម។ វិធីគណនាលម្អិតមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសនេះ។

**ប្រការ ១២.- អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ**

អ្នកជាប់ពន្ធត្រូវអនុវត្តអត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអត្រាពន្ធកំណើនតាមថ្នាក់ដូចមានចែងក្នុងមាត្រា២០ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ១៣.- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល**

អ្នកជាប់ពន្ធត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែ តាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការអាជីវកម្មបានកើតឡើង។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលត្រូវបានគណនាតាមអត្រា ១ ភាគរយ នៃផលរបររួមបញ្ចូលទាំងអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ“ផលរបរ” សំដៅដល់÷

ក- តម្លៃនៃការផ្គត់ផ្គង់ទំនិញឬសេវាដែលជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ

ខ- ទឹកប្រាក់លម្អៀងនៃថ្លៃទិញនិងថ្លៃលក់ ចំពោះការផ្គត់ផ្គង់ទំនិញឬសេវាដូចខាងក្រោម÷

- មាស ពេជ្រ ត្បូងថ្មមានតម្លៃ
- សេវាប្តូរប្រាក់

គ- កម្រៃដែលបានមកពីការធ្វើសេវានានាក្នុងនាមសហគ្រាសជាគោលដើម។

**ប្រការ ១៤.- ពន្ធអប្បបរមា**

ពន្ធអប្បបរមាត្រូវបានកំណត់តាមអត្រា ១ ភាគរយ លើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ អ្នកជាប់ពន្ធត្រូវបង់ពន្ធនេះនៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ជារៀងរាល់ខែក្នុងឆ្នាំជាប់ពន្ធត្រូវក្លាយជាពន្ធអប្បបរមាប្រចាំឆ្នាំដោយស្វ័យប្រវត្តិ។

**ប្រការ ១៥.- ការគណនាពន្ធលើប្រាក់ចំណូលត្រូវបង់**

ការគណនាពន្ធលើប្រាក់ចំណូលត្រូវបង់ក្នុងឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម÷

១- ក្នុងករណីពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ មានចំនួនលើសពីពន្ធអប្បបរមាដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមនូវចំនួនលម្អៀងលើស។

២- ក្នុងករណីពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ មានចំនួនតិចជាងពន្ធអប្បបរមាដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ ពន្ធអប្បបរមាត្រូវបានចាត់ទុកជាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

## ប្រការ ១៦.- ការយោងការខាតបង់

អ្នកជាប់ពន្ធមិនត្រូវបានអនុញ្ញាតឱ្យយោងការខាតបង់ក្នុងឆ្នាំជាប់ពន្ធណាមួយទៅឆ្នាំបន្តបន្ទាប់ឡើយ។

# ផ្នែកទី៣
# ពន្ធនិងអាករដទៃទៀត

## ប្រការ ១៧.- អាករលើតម្លៃបន្ថែម

១- អ្នកជាប់ពន្ធត្រូវអនុវត្តវិធាននិងនីតិវិធីសម្រាប់ការផ្គត់ផ្គង់ និងវិធាននៃការប្រើប្រាស់វិក្កយបត្រតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី៧ និងជំពូកទី៩ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម លេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩។

២- ចំពោះការគណនាអាករលើតម្លៃបន្ថែមដែលត្រូវបង់សម្រាប់ខែនីមួយៗ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលចំនួន ៨០ ភាគរយ សម្រាប់កាត់កងនឹងអាករលើធាតុចេញ ទោះបីជាអ្នកជាប់ពន្ធមានឬគ្មានវិក្កយបត្របញ្ជាក់អំពីអាករលើធាតុចូលក៏ដោយ។

៣- ចំពោះការផ្គត់ផ្គង់ទំនិញឬសេវាដូចមានចែងក្នុងកថាខណ្ឌ ខ នៃប្រការ ១៣ នៃប្រកាសនេះ អ្នកជាប់ពន្ធមិនត្រូវបានអនុញ្ញាតឥណទានអាករលើធាតុចូលឡើយ។

## ប្រការ ១៨.- ពន្ធអាករដទៃទៀត

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស និងបង់ពន្ធនិងអាករដទៃទៀតទៅតាមច្បាប់និងបទប្បញ្ញត្តិពន្ធដារជាធរមាន។

## ប្រការ ១៩.- កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

អ្នកជាប់ពន្ធមានកាតព្វកិច្ចដូចខាងក្រោម÷

១- ចុះបញ្ជីពន្ធដារស្របតាមប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤ ស្តីពីការចុះបញ្ជីពន្ធដារ។

២- ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនិងអាករនានាជាធរមាន ជូនរដ្ឋបាលសារពើពន្ធ តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន។

៣- ត្រូវកាន់កាប់កត់ត្រាបញ្ជីគណនេយ្យសាមញ្ញឱ្យបានត្រឹមត្រូវ និងត្រូវបង្ហាញបញ្ជីនេះព្រមទាំងឯកសារភស្តុតាងនានាជូនរដ្ឋបាលសារពើពន្ធ។

៤- ក្នុងករណីមិនបានកាន់កាប់កត់ត្រា ឬកត់ត្រាមិនត្រឹមត្រូវនូវបញ្ជីគណនេយ្យសាមញ្ញ ចំនួនប្រាក់ចំណូលនិងប្រាក់ចំណេញជាប់ពន្ធត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធតាមវិធីដូចខាងក្រោម÷

ក- ប្រាក់ចំណូលប្រចាំខែឬប្រចាំឆ្នាំ គឺជាចំនួនប៉ាន់ស្មានតាមរយៈការអង្កេតរបស់មន្ត្រីពន្ធដារ រកមធ្យមភាគ នៃចំណូលពីការផ្គត់ផ្គង់ទំនិញឬសេវា

ខ- ប្រាក់ចំណេញជាប់ពន្ធត្រូវបានកំណត់តាមអត្រាដូចខាងក្រោម÷

- ២០ ភាគរយ នៃប្រាក់ចំណូលប៉ាន់ស្មានសរុប ចំពោះការផ្គត់ផ្គង់ទំនិញ
- ៤០ ភាគរយ នៃប្រាក់ចំណូលប៉ាន់ស្មានសរុប ចំពោះការផ្គត់ផ្គង់សេវា ឬ
- ៥០ ភាគរយ ចំពោះការផ្គត់ផ្គង់ទំនិញឬសេវាដូចមានចែងក្នុងកថាខណ្ឌ ខ នៃប្រការ ១៣ នៃប្រកាសនេះ។

## ផ្នែកទី៤

## អវសានប្បញ្ញត្តិ

### ប្រការ ២០.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ ២១.- ការអនុវត្ត

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ឆ្នាំ២០១៥

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ